**ព្រះរាជាណាចក្រកម្ពុជា**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **ជាតិ សាសនា ព្រះមហាក្សត្រ**

ទូរសារ/ទូរស័ព្ទ: (៨៥៥)២៣ ២៧៧៥៨

លេខ : ០៣២ សហវ.សណ

## សេចក្តីណែនាំ

## ស្តីពីការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលតាមក្រសួង ស្ថាប័ន នៅរដ្ឋបាលកណ្តាលនិងតាមមន្ទីរនានានៅខេត្ត-ក្រុង

ផ្អែកតាមសេចក្តីប្រកាសលេខ ០១ ប្រក ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាលស្តីពីការកែទម្រង់រដ្ឋបាលសាធារណៈ និង សារាចរលេខ ០១ សរ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាលស្តីពីការរាប់ចំនួនមន្ត្រីរាជការស៊ីវិលទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ក្រោយពីកិច្ចប្រតិបត្តិការរាប់ចំនួនមន្ត្រីរាជការស៊ីវិលទូទាំងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ មកមានក្រសួងស្ថាប័នខេត្ត-ក្រុង មួយចំនួនបើកប្រាក់បៀវត្សជូនមន្ត្រីរាជការ ក្រោមឱវាទរបស់ខ្លួនមានការយឺតយ៉ាវ ដោយនៅមិនទាន់យល់ច្បាស់ពីមូលដ្ឋានដែលត្រូវបើកបៀវត្ស ជាពិសេសនៅតាមខេត្ត-ក្រុងខ្លះ ។

ដើម្បីជំរុញការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការឱ្យបានទាន់ពេលវេលានិងប្រកបដោយជោគជ័យនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចតទៅ ៖

១- ជំហានទី១ : ត្រូវបើកប្រាក់បៀវត្សជូនចំពោះតែមន្ត្រីរាជការស៊ីវិលណា ដែលមានសលាកបត្រមន្ត្រីរាជការនិងវិញ្ញាបនបត្រ បើកបៀវត្ស ដែលបានធ្វើនៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

២- ជំហានទី២ : ចំពោះមន្ត្រីរាជការ ដែលអវត្តមានដោយមានមូលហេតុច្បាស់លាស់ដូចជា ៖

- អ្នកកំពុងតែសិក្សាមានរយៈពេលខ្លី ឬ វែង ហើយមានលិខិតចាត់តាំងត្រឹមត្រូវ ,
- អ្នកដែលត្រូវអនុញ្ញាតច្បាប់ឱ្យឈប់សំរាករយៈពេលយូរ សំរាលកូន ឬ មានជំងឺរ៉ាំរ៉ៃ ឬ ត្រូវបានអនុញ្ញាតឱ្យទៅព្យាបាលជំងឺនៅបរទេស ,
- អ្នកត្រូវបានអនុញ្ញាតឱ្យចុះបំពេញបេសកកម្ម ដោយមានលិខិតបញ្ជាបេសកកម្មត្រឹមត្រូវ ,
- មន្ត្រីរាជការមួយចំនួនធ្វើការនៅតំបន់ដាច់ស្រយាលដូចជានៅខេត្តភូមិភាគឥសាន ឬ នៅខេត្តដទៃទៀត ដែលមានសភាពការណ៍អសន្តិសុខ ឬ ខ្វះមធ្យោបាយធ្វើដំណើរ មិនអាចឡើងមកទាន់ពេលវេលាដើម្បីបំពេញសលាកបត្រមន្ត្រីរាជការ និង វិញ្ញាបនបត្របើកបៀវត្ស ,
- អ្នកមានលិខិត ឬ សេចក្តីសំរេចផ្សេងៗទៀតដែលស្របច្បាប់ ។

ចំពោះមន្ត្រីរាជការស៊ីវិលដែលអវត្តមាន មានមូលហេតុតាមមុខសញ្ញាដូចបានបញ្ជាក់ខាងលើនេះនៅបន្តបើកប្រាក់បៀវត្សដូចធម្មតា ប៉ុន្តែប្រធានអង្គភាពគ្រប់គ្រងសាមីជននោះផ្ទាល់ ត្រូវធ្វើរបាយការណ៍បញ្ជាក់ទទួលខុសត្រូវពីមូលហេតុច្បាស់លាស់ដោយមានចុះហត្ថលេខា របស់មន្ត្រីតំណាងប្រធានបុគ្គលិកនិងតំណាងប្រធានគណនេយ្យ ដែលបានប្រគល់សិទ្ធិចុះហត្ថលេខាលើសលាកបត្រមន្ត្រីរាជការនិងវិញ្ញាបនបត្របើកបៀវត្ស នាថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ព្រមទាំងមានការបញ្ជាក់ពីឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការ ចំពោះក្រសួង ស្ថាប័ននៅរដ្ឋបាលកណ្តាលនិងនៅតាមខេត្តក្រុង ត្រូវមានបញ្ជាក់ពីអភិបាលខេត្ត-ក្រុង រួចបញ្ជូនរបាយការណ៍នេះមួយច្បាប់ជូនគណៈកម្មការត្រួតពិនិត្យមន្ត្រីរាជការស៊ីវិលនៅគណៈរដ្ឋមន្ត្រី ដើម្បីជ្រាប ។

-/-

៣_ ជំហានទី ៣ : ចំពោះមន្ត្រីរាជការទាំងឡាយណា ដែលមានទេញលិខិតទទួលស្គាល់ក្របខ័ណ្ឌពីគណៈរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ហើយត្រូវបានក្រសួង ឬ ស្ថាប័ន ខេត្ត_ក្រុង ចេញប្រកាសតែងតាំងប្រគល់ការងារជូនហើយនោះត្រូវរៀបចំបញ្ចូលក្នុងតារាងបៀវត្ស ដើម្បីរាយការណ៍សុំមកគណៈរដ្ឋមន្ត្រី " គណៈកម្មការត្រួតពិនិត្យរាជមន្ត្រីរាជការ " សំរេចបើកបៀវត្សជូន ។

៤_ ចំពោះមន្ត្រីរាជការ ដែលអវត្តមានដោយគ្មានមូលហេតុពីមិនអនុញ្ញាតអោយបើកប្រាក់បៀវត្សជូនទេ ទោះបីក្រោយថ្ងៃរាប់មានលិខិតសុំតវ៉ាក៏ដោយ ត្រូវរង់ចាំសេចក្តីសំរេចរបស់គណៈកម្មការ ត្រួតពិនិត្យមន្ត្រីរាជការស៊ីវិល នៅគណៈរដ្ឋមន្ត្រី ។

ដោយយោងតាមខ្លឹមសារខាងលើនេះ ក្រសួង ស្ថាប័ន ខេត្ត_ក្រុង ត្រូវយកចិត្តទុកដាក់បើកបៀវត្សជូនមន្ត្រីរាជការក្រោមឱវាទរបស់ខ្លួនឱ្យបានទាន់ពេលវេលា ។ –៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឆន់

<u>កន្លែងទទួល</u> :

- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជ្រាបជាពត៌មាន "
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់ខេត្ត_ក្រុង
  " ដើម្បីអនុវត្ត "
- កាលប្បវត្តិ_ឯកសារ